ទំនុកដំកើង១៤០-១៤៣

ជំពូក ១៤០

ជាតចនា *សេចក្តីអំពាវនាវសូមអោយរួចពីក្រញាំដៃ*
នៃមនុស្សអាក្រក់

នៅពេលយើងសិក្សាគម្ពីរទំនុកដំកើង យើងតែងជួបប្រទះនឹងជំពូកខ្លះចង
ក្រងគ្នាជាកន្សោម បញ្ជាក់ពីប្រធានបទណាមួយ។ ជួនកាលជំពូកខ្លះនិយាយដាច់ដោយ
ឡែកតែឯង។ ក្នុងករណីគម្ពីរទំនុកដំកើងជំពូក១៤០ ប្រធានបទឥតមានទាក់ទងនឹង
គោលទ្វិជ៍ធំ យើងឃើញមាននៅក្នុងជំពូក១៣៩ទេ។ ជំពូក១៤០ ជាបទទំនាយស្តីពី
សំណល់នៃសាសន៍អ៊ីស្រាអែល ដែលត្រូវរស់នៅឆ្លងកាត់គ្រាមហាទុក្ខ។ ពេលនោះ
គេត្រូវពើបប្រទះនឹងជនទទឹងនឹងព្រះគ្រីស្តជាព្រះគ្រីស្តក្លែងក្លាយ និងជាជនមេចាប។
ពេលព្រះចាទជាវិឌកត់ត្រាទុកជំពូក១៤០ ទ្រង់ស្ថិតនៅក្រោមគំនាបស្តេចសូល ដែល
តាមប្រហារជីវិតលោករៀងរាល់វិនាទី។ ស្តេចសូលមានចិត្តឫស្យា។ សាវ៉ែកប៉ុល
បរិយាយពីកិរិយារបស់ស្តេចអង្គនេះក្នុងគម្ពីរ២ថែស្សាឡូនីច។

ជំពូក១៤០ មានសេចក្តីពិតសម្រាប់លោកអ្នកហើយនិងរូបខ្ញុំ យកមកអនុវត្ត
ក្នុងពេលបច្ចុប្បន្ននេះ។

ឱព្រះយេហូវ៉ាអើយ សូមជ្រោសទូលបង្គំ ឱ្យរួចពីមនុស្សអាក្រក់ សូមការពារទូលបង្គំ ឱ្យរួចពីមនុស្សច្រឡោត (ទំនុកដំកើង ១៤០:១)។

ខ១សម្តែងពីបុគ្គលិកលក្ខណៈរបស់ជនទទឹងនឹងព្រះគ្រីស្ទ។ ជនទទឹងនឹងព្រះគ្រីស្ទ ជាមនុស្សដ៏អាក្រក់ និងជាមនុស្សច្រឡោត។ ជនទទឹងនឹងព្រះគ្រីស្ទមានចំនួនច្រើនឥតគណនា។ លោកយ៉ូហានសម្តែងនៅក្នុងគម្ពីរ១យ៉ូហាន២:១៨ថា "ក្មេងរាល់គ្នាអើយ នេះជាពេលម៉ោងក្រោយបង្អស់ហើយ សព្វថ្ងៃនេះកើតមានពួកទទឹងនឹងព្រះគ្រីស្ទជាច្រើន ដូចជាអ្នករាល់គ្នាបានឮហើយថា អាទទឹងនឹងព្រះគ្រីស្ទត្រូវមក ហេតុនោះបានជាយើងដឹងថា នេះជាពេលម៉ោងក្រោយបង្អស់"។ យើងតែងជួបនឹងមនុស្សប្រភេទនេះ គឺមនុស្សអាក្រក់និងមនុស្សច្រឡោត។ ព្រះបាទដាវីឌអធិស្ឋានសូមដល់ព្រះជាម្ចាស់ សូមទ្រង់ការពារលោកអោយរួចពីក្រញាំដៃនៃមនុស្សអាក្រក់ និងមនុស្សច្រឡោត។ ដូចគ្នាដែរ ពេលយើងបម្រើព្រះជាម្ចាស់ យើងត្រូវអធិស្ឋានសូមព្រះជាម្ចាស់ថា "ឱព្រះអង្គអើយ សូមកុំបណ្តោយអោយទូលព្រះបង្គំយើងខ្ញុំ ស្ថិតនៅក្រោមអំណាចនៃមនុស្សអាក្រក់ និងមនុស្សច្រឡោតឡើយ"។ ត្រួតង្វាលដែលស្ថិតនៅក្រោមឥទ្ធិពលឥស្សរជនក្នុងក្រុមជំនុំ ជាមនុស្សអាក្រក់ និងជាមនុស្សច្រឡោត មានគ្រោះថ្នាក់ណាស់។ ក្រុមជំនុំនោះមិនបានធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ គឺធ្វើតាមតែគំនិតរបស់ជនច្រឡោតនោះវិញ។

[២]ជាអ្នកដែលតែងមានចិត្តគិតគូរការអាក្រក់ ហើយចេះតែលើកគ្នាចង់ធ្វើចំបាំងជានិច្ច [៣]គេបានសំលៀងអណ្តាតគេ ឱស្ត្រូចអួចជាអណ្តាតពស់ ក៏មានពិសពស់ហនុមាននៅក្រោមបបូរមាត់គេ។ -បង្អង់ (ទំនុកដំកើង១៤០:២-៣)។

ខខាងលើបញ្ជាក់ពីចរិតរបស់មនុស្សលោក ដែលរស់នៅលើផែនដីរបស់ព្រះជាម្ចាស់។ សាវ័កប៉ុលក៏បញ្ជាក់ពីទឹកចិត្តរបស់ពូជមនុស្សលោកក្នុងគម្ពីររ៉ូម៣:១០-១៨ ដែរ។ អណ្តាតរបស់មនុស្សលោកមានពិសពុល។ ដូចគ្រាប់បែកបរមាណូ។ អណ្តាតរបស់មនុស្ស ធ្វើអោយកេរ្តិ៍ឈ្មោះអ្នកដទៃខូចខាត។ មិនតែប៉ុណ្ណោះ អណ្តាតរបស់មនុស្សលាបពណ៌ជីវិតមនុស្សដទៃៗថែមទៀតផង។

ឱព្រះយេហូវ៉ាអើយ សូមថែរក្សាទូលបង្គំឱ្យរួចពីដៃនៃមនុស្សអាក្រក់ សូមការពារទូលបង្គំឱ្យរួចពីមនុស្សច្រឡោត ជាអ្នកដែលបានសំរេចចិត្តនឹងធ្វើឱ្យទូលបង្គំភ្លាត់ក្នុងផ្លូវប្រព្រឹត្ត (ទំនុកដំកើង ១៤០:៤)។

ខខាងលើជាសេចក្តីអធិស្ឋានរបស់ព្រះបាទដាវីឌ និងជាសេចក្តីអធិស្ឋានរបស់សាសន៍អ៊ីស្រាអែលសេសសល់ ដែលត្រូវរស់នៅឆ្លងកាត់គ្រាមហាទុក្ខ។ ចំពោះគ្រីស្ត

បរិស័ទ យើងមិនត្រូវអធិស្ឋានដូចខខាងលើនេះទេ។ សាសន៍អ៊ីស្រាអែលដែលស្ថិតនៅក្រោមអំណាចក្រីក្យវិន័យ គេមានសិទ្ធអធិស្ឋានសូមអោយព្រះជាម្ចាស់សម្រេចការជំនុំជំរះរបស់ទ្រង់ដ៏សុចរិតនៅក្នុងពេលដែលគេរស់នៅឆ្លងកាត់គ្រាមហាទុក្ខ។

[9]ឱព្រះយេហូវ៉ាអើយ សូមទ្រង់កុំអនុញ្ញាតដល់ពួកមនុស្សអាក្រក់តាមអំពើចិត្តគេឡើយ ក៏កុំឱ្យកិច្ចកលរបស់គេបានជៀនទៅដែរ ក្រែងគេអួតខ្លួន។ -បង្អង់ [9]ឯក្បាលនៃពួកអ្នកដែលព័ទ្ធខ្ញុំបង្គំជុំវិញ នោះសូមឱ្យអំពើអាក្រក់របស់បបូរមាត់គេ បានធ្លាក់ទៅលើគេវិញ [10]សូមឱ្យមានរងើកភ្លើងឆេះ ធ្លាក់ទៅលើគេ ហើយឱ្យគេត្រូវចោះទៅក្នុងភ្លើង គឺទៅក្នុងរណ្តៅយ៉ាងជ្រៅ គឺឯឡើងមកមិនរួចឡើយ (ទំនុកដំកើង១៤០:៨-១០)។

អ្នកកត់ត្រាគម្ពីរទំនុកដំកើងជំពូក១៤០ អធិស្ឋានទាស់ទទឹងនឹងមនុស្សអាក្រក់ជាជនទទឹងនឹងព្រះគ្រីស្ត។ គ្រីស្ទបរិស័ទមិនត្រូវអធិស្ឋានដូចសេចក្តីដែលមានចែងនៅក្នុងខខាងលើនេះទេ។ ចំពោះយើងជាគ្រីស្ទបរិស័ទ តើយើងត្រូវអធិស្ឋានដូចម្តេចវិញ? យើងត្រូវអធិស្ឋាន ដូចសាវ័កប៉ុលបង្ហាត់បង្រៀនយើងក្នុងគម្ពីររ៉ូម១២:១៩-២១ថា "ឱពួកស្ងួនភ្ងាអើយ កុំឱ្យសងសឹកឡើយ ចូរថយចេញពីសេចក្តីកំហឹងទៅ ដ្បិតមានសេចក្តីចែងទុកមកថា "ព្រះអម្ចាស់ ទ្រង់មានបន្ទូលថា ការសងសឹក នោះស្រេចនឹង

អញ អញនឹងសងដល់គេ" ដូច្នេះ បើសិនណាជាខ្មាំងសត្រូវអ្នកឃ្លាន នោះចូរឱ្យគេបរិភោគចុះ បើគេស្រេក ចូរឱ្យផឹកទៅ បើប្រព្រឹត្តដូច្នោះ នោះដូចជាអ្នកបានប្រមូលរងើកភ្លើង ដាក់លើក្បាលគេវិញ កុំឱ្យសេចក្តីអាក្រក់ឈ្នះអ្នកឡើយ ត្រូវឱ្យអ្នកឈ្នះសេចក្តីអាក្រក់ ដោយសារសេចក្តីល្អវិញ"។ សាវ័កប៉ុលដាស់តឿនយើង មិនត្រូវបង្កៃសេចក្តីជូរល្វីងអោយដក់នៅក្នុងចិត្តយើងជាដាច់ខាត។ ម្យ៉ាងទៀត យើងមិនត្រូវបណ្តោយអោយសត្រូវដឹកនាំយើង ប្រើអំពើហិង្សាជាដំណោះស្រាយទំនាស់ទេ។ បើយើងប្រើហិង្សាដោះស្រាយទំនាស់ យើងកំពុងតែប្រកាសជាសាធារណៈថា យើងឈប់ទុកចិត្តដល់ព្រះជាម្ចាស់ហើយ។ យើងត្រូវជឿថា ព្រះជាម្ចាស់អាចដោះស្រាយរឿងរ៉ាវរបស់យើងបាន។ បើយើងដកដៃពីការសងសឹក ព្រះជាម្ចាស់ចូលមកបំពេញតួនាទី ដើម្បីសម្រេចក្តីរបស់ទ្រង់ ចំពោះជនដែលធ្វើជាឧបសគ្គដល់ការងាររបស់ព្រះអង្គ។ ការសងសឹកស្រេចនៅលើព្រះជាម្ចាស់។ ចំពោះយើងជាគ្រីស្ទបរិស័ទ ត្រូវផ្ទេរបន្ទុកនោះថ្វាយដាច់ដល់ព្រះជាម្ចាស់។ បន្ទាប់ពីផ្ទេរបន្ទុកដល់ព្រះជាម្ចាស់ហើយ លោកអ្នកពិតជាមានចិត្តល្អចំពោះបុគ្គលដែលបៀតបៀនលោកអ្នក។ ពេលនោះ ព្រះជាម្ចាស់អោយយើងឆ្លងកាត់ហេតុការណ៍មួយ ដែលខុសប្លែកពីមនុស្សធម្មតា។

មនុស្សដែលមានអណ្តាតអាក្រក់ នោះមិនដែលបានតាំងឡើង ឱ្យមាំមួននៅផែនដីឡើយ ឯមនុស្សច្រឡោតនឹងមានសេចក្តីអាក្រក់ដេញតាមបំផ្លាញគេ (ទំនុកដំកើង១៤០:១១)។

បើយើងនៅតែទុកចិត្តដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងត្រាកដជាមានជោគជ័យ។ គម្ពីរ១យ៉ូហាន៥:៤សម្តែងថា "ពីព្រោះគ្រប់ទាំងអស់ដែលកើតពីព្រះមក នោះបានឈ្នះលោកិយហើយ ឯជ័យជំនះដែលឈ្នះលោកិយ នោះគឺជាសេចក្តីជំនឿរបស់យើង"។ អណ្តាតមូលបង្កាច់មិនអាចសម្រេចការអ្វីបានទេ។ អំពើភូតភររបស់ គេពិតជាត្រូវគេដេញជើងទាន់ថ្ងៃណាមួយជាមិនខាន។ សាតាំងជាមេភូតភរពីដើម មក។ សាតាំងមានកូនចាប កូនព្រាបវារាប់រយរាប់ពាន់ក្បាលសព្វថ្ងៃនេះ។ កូនចាប កូនព្រាបរបស់សាតាំង ប្រើអណ្តាតភូតភរដូចឪពុកវាដែរ។ ព្រះជាម្ចាស់មានន័យធ្វើអោយពាក្យភូតភររបស់សាតាំង និងពួកពលបរិវារបស់វាត្រូវគេដេញជើងទាន់។

ជំពូក ១៤១

ជាឥចនា *សេចក្តីអំពាវនាវសូមអោយរួចពីការអាក្រក់*

ព្រះចាទដាវីឌកត់ត្រាទុកទំនុកដំកើងជំពូក១៤១។ ទ្រង់កត់ត្រាទុកវាងពេលលោករត់គេចពីការតាមប្រហារជីវិតរបស់ស្តេចសុល។ ជាការអនុវត្តន៍សម្រាប់សាសន៍អ៊ីស្រាអែលសេសសល់ ដែលត្រូវរស់កាត់គ្រាមហាទុក្ខ។ ក៏ដូចជាការអនុវត្តន៍របស់យើងជាគ្រីស្ទបរិស័ទសព្វថ្ងៃនេះដែរ។

[1]ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់ទ្រង់ហើយ សូមប្រញាប់នឹងយាងមកឯទូលបង្គំ សូមផ្ទៀងព្រះកាណ៌ស្តាប់សំឡេងទូលបង្គំ ក្នុងកាលដែលទូលបង្គំអំពាវនាវដែរ [2]សូមឱ្យសេចក្តីអធិស្ឋានរបស់ទូលបង្គំបានផ្សាយឡើង ដូចជាគ្រឿងក្រអូបនៅចំពោះទ្រង់ នឹងការលើកដៃប្រណម្យរបស់ទូលបង្គំ បានដូចជាយញ្ញបូជាពេលល្ងាច (ទំនុកដំកើង១៤១:១-២)។

នៅក្នុងជីវិតរបស់លោក ព្រះចាទដាវីឌចូលចិត្តអធិស្ឋានអំពាវនាវដល់ព្រះជាម្ចាស់ណាស់។ លោករស់នៅដោយការអធិស្ឋាន។ ស្តេចដាវីឌបញ្ជាក់ថា "សូមឱ្យ

សេចក្តីអធិស្ឋានរបស់ទូលព្រះបង្គំបានផ្សាយឡើងដូចជាយញ្ញបូជាពេលល្ងាច"។ សេចក្តីអធិស្ឋានដែលយើងទូលសូមដល់ព្រះជាម្ចាស់ក្នុងនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាភ្លិនក្រអូបនៅចំពោះបល្ល័ង្ករបស់ព្រះជាម្ចាស់។ ប៉ុន្តែ មិនមែនសេចក្តីអធិស្ឋានទាំងអស់ក្នុងនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ សុទ្ធតែជាភ្លិនក្រអូបសាយដល់បល្ល័ង្កទ្រង់ទេ។ សេចក្តីអធិស្ឋានដែលមានភ្លិនក្រអូបសាយឡើងដល់បល្ល័ង្កទ្រង់ មានភិនភាគពីរយ៉ាង។ មួយ សេចក្តីអធិស្ឋាននោះ ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់ ដោយស្មោះអស់ពីដួងចិត្ត។ ពីរ សេចក្តីអធិស្ឋាននោះ ត្រូវគាំទ្រដោយជីវិតអ្នកអធិស្ឋាន ដោយចេះចូល ព្រមទាំងស្តាប់បង្គាប់ដល់ព្រះជាម្ចាស់។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ បង្រៀនពីសេចក្តីអធិស្ឋាន ដែលមានភ្លិនក្រអូបសាយដល់បល្ល័ង្ករបស់ព្រះជាម្ចាស់ ក្នុងគម្ពីរយ៉ូហាន១៤:១៤-១៥ថា "បើអ្នករាល់គ្នានឹងសូមអ្វីដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឱ្យ បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ"។ យោងតាមព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទត្រង់ចំណុចនេះ សេចក្តីអធិស្ឋានក្នុងព្រះនាមព្រះអង្គ មិនមែនសុទ្ធតែជាគ្រឿងក្រអូបទេ។ បើលោកអ្នកចង់អោយព្រះជាម្ចាស់ឆ្លើយតបនឹងសេចក្តីអធិស្ឋាន លោកអ្នកត្រូវទូលសូមដោយមានជីវិតបរិសុទ្ធគាំទ្រសេចក្តីអធិស្ឋាននោះ។

ឱព្រះយេហូវ៉ាអើយ សូមទ្រង់ដាក់ការយាម នៅមាត់ទូលបង្គំ ហើយថែរក្សាទ្វារបបូរមាត់របស់ទូលបង្គំផង (ទំនុកដំកើង១៤១:៣)។

ព្រះបាទដាវីឌទូលសូមដល់ព្រះជាម្ចាស់ថា "...សូមទ្រង់ដាក់ការយាមនៅមាត់ទូលបង្គំ ហើយថែរក្សាទ្វារបបូរមាត់របស់ទូលបង្គំផង"។ ក្នុងករណីនេះ ហ្លួងដាវីឌចង់បញ្ជាក់ថា មិនអោយបបូរមាត់ហើយនិងជីវិតរបស់ហ្លួងមានភាពផ្ទុយគ្នា។ ចំណែកយើងជាគ្រីស្ទបរិស័ទដូចគ្នាដែរ ថ្ងៃអាទិត្យយើងមិនត្រូវធ្វើដូចជាស្រឡាញ់ព្រះជាម្ចាស់ឯថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ចាត់ទុកព្រះជាម្ចាស់ដូចជាព្រះស្លាប់នោះទេ។ ជីវិតដែលរស់នៅក្នុងដំណាក់ព្រះបែបណា ត្រូវអោយជីវិតនោះរស់នៅក្នុងភូមិស្រុកយ៉ាងដូច្នោះដែរ។

៤ សូមកុំឱ្យចិត្តទូលបង្គំល្អៀងទៅខាងសេចក្តីអាក្រក់ណា ដើម្បីប្រព្រឹត្តការអាក្រក់ជាមួយនឹងមនុស្ស ដែលតែងតែធ្វើការទុច្ចរិតឡើយ ហើយកុំឱ្យទូលបង្គំទទួលទានចំណីថ្នាញ់របស់គេឱ្យសោះ ៥ សូមឱ្យមនុស្សសុចរិតវាយទូលបង្គំចុះ នោះនឹងបានជាគុណ ហើយឱ្យគេប្រដៅទូលបង្គំផង នោះនឹងបានដូចជាប្រេងចាក់លាបលើក្បាល ឯក្បាលរបស់ទូលបង្គំនឹងមិនប្រកែកទេ ដ្បិតទូលបង្គំនឹងនៅតែអធិស្ឋាន ក្នុងកាលដែលកើតមានសេចក្តីអាក្រក់ផង (ទំនុកដំកើង១៤១:៤-៥)។

បន្ទាប់ពីព្រះអម្ចាស់ជ្រោសលោះយើងរួចពីអំពើចាបហើយ ព្រះអង្គមិនបានដកជីវិតយើងយកទៅស្ថានសួគ៌ភ្លាមៗទេ។ ព្រះអង្គអោយយើងរស់នៅក្នុងលោកនេះ

ធ្វើជាពន្លឺបំភ្លឺដល់មនុស្សលោកដែលរស់ក្នុងសេចក្តីងងឹត។ បើយើងជាកូនព្រះរស់នៅដូចមនុស្សមានចាបដែរ លោកអ្នកមិនត្រូវសង្ឃឹមថា ព្រះជាម្ចាស់ឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់លោកអ្នកទេ។ គម្ពីរទំនុកដំកើង៦៦:១៨ចែងថា "បើប្រសិនជាខ្ញុំឃើញមានសេចក្តីទុច្ចរិតនៅក្នុងចិត្ត នោះព្រះអម្ចាស់ទ្រង់មិនព្រមស្តាប់ខ្ញុំទេ"។ ព្រះជាម្ចាស់មិនដែលសន្យាថា ទ្រង់ស្តាប់សេចក្តីអធិស្ឋានរបស់មនុស្សអាក្រក់ឡើយ។ ព្រះអង្គមានបន្ទូលថា "ដូច្នេះ ចូរឱ្យអ្នករាល់គ្នាលន់តួទោសនឹងគ្នា ហើយអធិស្ឋានឱ្យគ្នាទៅវិញទៅមក ដើម្បីឱ្យបានជាចុះ ដ្បិតសេចក្តីទូលអង្វរជ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់" (យ៉ាកុប៥:១៦)។ ១យ៉ូហាន៣:២២ចែងដែរថា "ហើយទោះបើយើងសូមអ្វីពីទ្រង់ក៏ដោយ គង់តែនឹងបានសំរេច ពីព្រោះយើងកាន់តាមបញ្ញត្តទ្រង់ ហើយក៏ប្រព្រឹត្តការដែលគាប់ព្រះហឫទ័យដល់ទ្រង់ដែរ"។ ហ្លួងដាវីឌទូលសូមដល់ព្រះជាម្ចាស់អោយទ្រង់ដាក់ការចាំយាម ព្រមទាំងថែរក្សាទ្វារបបូរមាត់របស់ហ្លួងផង។ នៅក្នុងចិត្តរបស់លោកដាវីឌ លោកមិនចង់អោយចិត្តរបស់លោកទោរទន់ទៅរកអំពើអាក្រក់ទេ។ យើងជាគ្រីស្ទបរិស័ទត្រូវដើរតាមលំអានដានរបស់ស្តេចដាវីឌ បើយើងចង់អោយសេចក្តីអធិស្ឋានរបស់យើងបានឮដល់បល្ល័ង្កនៃព្រះដ៏ខ្ពស់បំផុត។

"ដ្បិត ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ ភ្នែកទូលបង្គំមើលចំទៅឯទ្រង់ ទូលបង្គំពឹងជ្រកនៅក្នុងទ្រង់ សូមកុំចោះបង់ចោលព្រលឹងនៃទូលបង្គំឡើយ "សូមរក្សាទូលបង្គំឱ្យរួចពីអន្ទាក់ ដែលគេបាន

ដាក់សំរាប់ចាប់ទូលបង្គំ ហើយពីអស់ទាំងអង្គប់របស់ពួកអ្នក ដែលប្រព្រឹត្តអំពើទុច្ចរិតផង (ទំនុកដំកើង១៤១:៨-៩)។

ហ្លួងដាវីឌទូលសូមដល់ព្រះជាម្ចាស់ កុំអោយលោកធ្លាក់ចូលទៅក្នុងអន្ទាក់ដែលមនុស្សអាក្រក់បានវាតទុក។ មនុស្សអាក្រក់ព្យាយាមបំផ្លាញយើងដោយប្រើគ្រប់មធ្យោបាយ ទាញយើងអោយជាប់អន្ទាក់របស់គេ។ តាមបទពិសោធន៍ផ្ទាល់របស់ខ្ញុំ គ្រីស្ទបរិស័ទដែលទុកចិត្តដល់ព្រះជាម្ចាស់ មិនសូវស្គាល់ផែនការអាក្រក់របស់សាតាំង និងអន្ទាក់ដែលគេបានលាតទុកសម្រាប់ខ្លួនឡើយ។ គ្រីស្ទបរិស័ទសាច់ឈាម ពោលគឺជាគ្រីស្ទបរិស័ទបន្ទំខ្លួនធ្វើជាអ្នកជឿ មានចិត្តឆ្លាតវាងវៃជាងគ្រីស្ទបរិស័ទ ដែលស្រឡាញ់ព្រះជាម្ចាស់។ រឿងនេះ សាវ័កប៉ុលបរិយាយក្នុងគម្ពីរ២កូរិនថូស២:១១ដែរ។

ប៉ុន្តែ យើងមានសេចក្តីសង្ឃឹមតែម្យ៉ាង គឺព្រះជាម្ចាស់ស្គាល់អន្ទាក់របស់សាតាំង ដែលលាតដាក់សម្រាប់ចាប់អ្នកស្មោះត្រង់ជាមួយនឹងព្រះអង្គ។ ដូច្នេះ យើងត្រូវអធិស្ឋានសូមអោយព្រះជាម្ចាស់ ជួយដោះយើងរួចពីអន្ទាក់របស់សាតាំង។

ជំពូក ១៤២

ឆាឆនា *ដាវីឌចាប់ផ្តើមទទួលទុក្ខលំបាក*

ជំពូក១៤២ ជាទំនុករបស់ព្រះចាទដាវីឌសរសេរឡើងសម្រាប់ជាសេចក្តីបង្រៀន។ អោយយើងចេះអធិស្ឋាន។ ជំពូកនេះជាសេចក្តីអធិស្ឋាន ដែលព្រះចាទដាវីឌទូលថ្វាយដល់ព្រះជាម្ចាស់ ពេលលោកកំពុងពួននៅក្នុងរអាងភ្នំ។

ទូលបង្គំស្រែកទូលដល់ព្រះយេហូវ៉ា ដោយសំឡេងនៃទូលបង្គំ គឺដោយសំឡេងរបស់ទូលបង្គំ ដែលទូលបង្គំទូលអង្វរដល់ព្រះយេហូវ៉ា (ទំនុកដំកើង១៤២:១)។

បើតាមការសន្និដ្ឋានរបស់ខ្ញុំ ហ្លួងដាវីឌកត់ត្រាទុកគម្ពីរទំនុកដំកើងជំពូក១៤២ ពេលដែលពួននៅក្នុងរអាងភ្នំអាឌូឡាម។ គម្ពីរ១សាំយូអែល២២:២ចែងថា "ហើយអស់អ្នកណាដែលមានសេចក្តីវេទនា នឹងអស់អ្នកណាដែលជាប់បំណុល ហើយនឹងអស់អ្នកណាដែលមានសេចក្តីជូរជ្រេញក្នុងចិត្ត គេក៏ទៅមូលជុំគ្នានៅឯលោក មានចំនួនប្រហែលជា៤០០នាក់នៅជាមួយនឹងលោក ហើយលោកធ្វើជាមេលើគេ"។ នៅក្នុង

អំឡុងពេលនោះ មានមនុស្សបួនរយនាក់រត់ចូលទៅខាងហ្លួងដាវីឌ។

សូមយើងពិចារណាសេចក្តីអធិស្ឋានរបស់ស្តេចដាវីឌ យ៉ាងពិស្តារដូចខាងក្រោមនេះ

ទូលបង្គំបង្ហូរសេចក្តីទំនួញរបស់ទូលបង្គំចេញ នៅចំពោះទ្រង់ ហើយក្រាបទូលពីសេចក្តីទុក្ខលំបាករបស់ទូលបង្គំ នៅចំពោះទ្រង់ដែរ (ទំនុកដំកើង១៤២:២)។

នៅក្នុងសេចក្តីអធិស្ឋាន ព្រះបាទដាវីឌទូលសូមដល់ព្រះជាម្ចាស់នូវសេចក្តីទាំងឡាយ ដែលមាននៅក្នុងចិត្តនិងជីវិតរបស់លោក។ យើងត្រូវអធិស្ឋានទូលសូមដល់ព្រះជាម្ចាស់យ៉ាងដូច្នោះដែរ។ ពេលយើងអធិស្ឋានយើងមិនត្រូវយកហេតុការណ៍មកពន្យល់ ឬយកមូលហេតុមកការពារកិរិយាប្រព្រឹត្តរបស់យើងទេ។ ព្រះជាម្ចាស់ជ្រាបអស់ទាំងហេតុការណ៍ដែលយើងកំពុងឆ្លងកាត់។ បើលោកអ្នកបានប្រព្រឹត្តអំពើបាបណាមួយ ព្រះអង្គក៏ជ្រាបរួចហើយថា ពេលលោកអ្នកប្រព្រឹត្តអំពើបាបនោះ លោកអ្នកធ្វើអ្វីខ្លះ ពេលណា ហើយធ្វើបែបណា។ ដូច្នេះ ពេលដែលលោកអ្នកចូលទៅចំពោះព្រះជាម្ចាស់ លោកអ្នកត្រូវទូលថ្វាយដល់ព្រះជាម្ចាស់ នូវរឿងតូចធំសព្វគ្រប់អស់សេចក្តីដោយមិនចាំបាច់ពន្យល់ដល់ព្រះជាម្ចាស់ពីមូលហេតុ ដែលលោកអ្នកធ្វើការនោះទេ។ លោកអ្នកត្រូវទូលថ្វាយដល់ព្រះជាម្ចាស់តាមត្រង់អស់ពីក្នុងចិត្តតែម្តង។ បើលោកអ្នក

ប្រព្រឹត្តអំពើបាប សូមទូលថ្វាយដល់ព្រះជាម្ចាស់នូវស្ថានភាពរបស់អំពើបាបនោះ។ បើលោកអ្នកកំពុងជួបសេចក្តីល្បួង លោកអ្នកត្រូវទូលថ្វាយដល់ព្រះជាម្ចាស់ថា លោកអ្នកកំពុងទប់ទល់នឹងសេចក្តីល្បួង មិនដឹងជាឈ្នះឬចាញ់ទេ សូមទ្រង់ជួយផង។ លោកអ្នកចាំបាច់ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់នូវរឿងសព្វគ្រប់ ឥតមានសេសសល់អ្វីឡើយ។ ខ្ញុំឃើញមានគម្រូអធិស្ឋានមួយ ដែលអ្នកបរិសុទ្ធរបស់ព្រះអង្គបានសរសេរកន្លងមក។ សេចក្តីអធិស្ឋាននោះមានខ្លឹមសារដូចតទៅ:

> "ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់ នូវអ្វីដែលមានលាក់កំបាំងនៅក្នុងចិត្ត បន្ទុកណាដែលយើងមាន សម្រើបណាដែលយើងកំពុងត្រេកត្រអាល សេចក្តីឈឺចាប់ណាដែលយើងកំពុងឆ្លងកាត់ សេចក្តីឈឺចាប់ណាដែលយើងកំពុងទទួល សូមទូលថ្វាយដល់ព្រះជាម្ចាស់អោយអស់សេចក្តីទាំងនោះចុះ។ ត្រូវទូលថ្វាយដល់ព្រះពីទុក្ខលំបាក ដ្បិតទ្រង់ជាអង្គដែលកំសាន្តចិត្ត។ ត្រូវទូលថ្វាយដល់ព្រះជាម្ចាស់នូវសេចក្តីរីករាយ ដើម្បីអោយទ្រង់ជួយផ្លាស់ប្រែសេចក្តីរីករាយនោះទៅជាសេចក្តីអំណរ។ ទូលថ្វាយដល់ព្រះជាម្ចាស់នូវ សេចក្តីប៉ងប្រាថ្នាអាក្រក់ទាំងអម្បាលមាណ ដើម្បីអោយទ្រង់ជួយសម្អាតចិត្តយើង។ ទូលថ្វាយដល់ព្រះជាម្ចាស់ពីសេចក្តីដែលលោកអ្នកមិនចូលចិត្ត ដើម្បីអោយព្រះជាម្ចាស់ជួយអោយលោកអ្នក យកជ័យជំនះលើចិត្តមិនល្អរបស់លោកអ្នក។

ទូលថ្វាយដល់ព្រះជាម្ចាស់នូវសេចក្តីល្បួងដែលលោកអ្នកកំពុងឆ្លងកាត់ ដើម្បីអោយព្រះជាម្ចាស់ធ្វើជាខែល បិទបាំងលោកអ្នកកុំអោយធ្លាក់ទៅក្នុងសេចក្តីល្បួងនោះ។ ទូលថ្វាយដល់ព្រះជាម្ចាស់នូវរបួសដែលមាននៅក្នុងចិត្ត ដើម្បីអោយព្រះជាម្ចាស់ព្យាបាលដល់លោកអ្នក។ ទូលថ្វាយដល់ព្រះជាម្ចាស់ នូវចិត្តរបស់លោកអ្នកមិនព្រមចង់ធ្វើអំពើល្អ ដើម្បីអោយព្រះជាម្ចាស់ជួយអោយលោកអ្នកមានលំនឹងក្នុងព្រលឹង។ ទូលថ្វាយដល់ព្រះជាម្ចាស់ថា លោកអ្នកមានកិរិយាអាត្មានិយម ដើម្បីអោយព្រះជាម្ចាស់ជួយលោកអ្នកកុំអោយលោកអ្នក មានសេចក្តីអំនួតនៅក្នុងចិត្ត។ ទូលថ្វាយដល់ព្រះជាម្ចាស់នូវ សេចក្តីទន់ខ្សោយ នូវសេចក្តីត្រូវការ នូវទុក្ខលំបាក ដើម្បីអោយព្រះជាម្ចាស់ផ្តាស់យើងបំប្រែយើងសារជាថ្មីឡើងវិញ។ ទូលថ្វាយដល់ព្រះជាម្ចាស់នូវសេចក្តីពោរពេញ ដែលមាននៅក្នុងចិត្ត ដើម្បីថ្វាយដល់ព្រះជាម្ចាស់អោយទ្រង់ជាអ្នកដែលសម្រេចសេចក្តីទាំងនោះ"។

ព្រះចាទដាវីឌមានទំនាក់ទំនងយ៉ាងស្និទ្ធិស្នាលជាមួយនឹងព្រះជាម្ចាស់ ដ៏មានព្រះជន្មរស់។ ស្តេចអង្គនេះទូលថ្វាយដល់ព្រះជាម្ចាស់នូវរឿងរ៉ាវទាំងអម្បាលមាណដែលមាននៅក្នុងចិត្តលោក។

ព្រះចាទដាវីឌទូលដល់ព្រះជាម្ចាស់ថា "ទូលបង្គំបង្ហូរសេចក្តីទំនូញរបស់ទូល

បង្គំចេញ នៅចំពោះទ្រង់ ហើយក្រាបទូលពីសេចក្តីទុក្ខលំបាករបស់ទូលបង្គំនៅចំពោះទ្រង់ដែរ"។ ក្នុងពេលនេះ ដាវីឌជាយុវជនមួយរូបដែលស្តេចសូលកំពុងដេញតាមប្រហារជីវិតលោក។ លោកបម្រើស្តេចសូលដោយអស់ពីចិត្ត តែស្តេចសូលបានពួយដែកពួយដើម្បីសម្លាប់លោក។ លោករត់គេចពីស្តេចសូលដូចជាសត្វក្រួចរត់គេចពីនាយព្រាន។ ធម្មតាព្រានព្រៃដេញចាប់សត្វក្រួចនៅពេលរដូវចម្រូត។ ចំណែកស្តេចសូលដេញប្រហារជីវិតលោកដាវីឌ គ្មានរដូវកាលទេ។ ដូច្នេះបានជាយុវជនដាវីឌអំពាវនាវទូលសូមដល់ព្រះជាម្ចាស់ ដើម្បីអោយទ្រង់ជួយដល់លោកផង។

កាលវិញ្ញាណទូលបង្គំបានអន់ថយនៅក្នុងខ្លួន នោះទ្រង់បានស្គាល់ផ្លូវច្រករបស់ទូលបង្គំ គេបានដាក់អន្ទាក់លាក់កំបាំងក្នុងផ្លូវដែលទូលបង្គំដើរ (ទំនុកដំកើង១៤២:៣)។

ស្តេចសូលនិងកងទ័ពរបស់ទ្រង់ បានរាយអន្ទាក់ដាក់បង្កាត់ ព្រមទាំងប្រើគ្រប់មធ្យោបាយដើម្បីចាប់ដាវីឌ។ ចំណែកដាវីឌវិញ សម្លឹងមើលទៅព្រះជាម្ចាស់អោយទ្រង់ជួយជីកនាំជីវិតលោក។

សូមទតទៅខាងស្តាំមើល ដ្បិតគ្មានអ្នកណាស្គាល់ទូលបង្គំសោះ គ្រប់ទាំងទីពឹងបានចាត់ពីទូលបង្គំចេញហើយ ឥតមានអ្នកណា

រវល់នឹងព្រលឹងទូលបង្គំឡើយ (ទំនុកដំកើង១៤២:៤)។

ពេលដាវីឌរត់គេចចេញពីរាជវាំងរបស់ស្តេចសូល លោករត់ទៅតែម្នាក់ឯង។ ក្រោយមកមានមនុស្សបួនរយនាក់ទៀត បានចូលរួមជាមួយនឹងលោក។ ព្រះជាម្ចាស់បានផ្តល់ការលើកទឹកចិត្តដល់លោកដាវីឌ ដោយបញ្ជូនមនុស្សបួនរយនាក់អោយគាំទ្រលោក។

ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់ទ្រង់ ទូលបង្គំបានពោលថា ទ្រង់ជាទីពឹងរបស់ទូលបង្គំ គឺជាចំណែកនៃទូលបង្គំនៅក្នុងស្ថានរបស់មនុស្សរស់នេះ (ទំនុកដំកើង១៤២:៥)។

ដាវីឌចាំបាច់រត់គេចពួនខ្លួនក្នុងរអាងភ្នំ ដើម្បីអោយរួចពីការតាមប្រហារជីវិតរបស់លោកសូល។ ដាវីឌទុកចិត្តដល់ព្រះជាម្ចាស់ តែលោកចាំបាច់ត្រូវប្រើគំនិតសុភវិនិច្ឆ័យ ដើម្បីការពារជីវិតរបស់ខ្លួន។ ព្រះជាម្ចាស់ផ្តល់គំនិតសុភវិនិច្ឆ័យដល់មនុស្សគ្រប់រូបសម្រាប់ប្រើក្នុងការរស់នៅប្រចាំថ្ងៃ។

ជំពូក ១៤៣

ជាតជនា ស្តេចដាវីឌអំពាវនាវសូមជំនួយពីព្រះជាម្ចាស់

ហ្លួងដាវីឌកត់ត្រាទុកសេចក្តីអធិស្ឋានមួយទៀត ក្នុងគម្ពីរទំនុកដំកើងជំពូក ១៤៣។ ស្ថានភាពរបស់ហ្លួងមានការតានតឹងណាស់ហើយ បានជាហ្លួងអំពាវនាវដល់ព្រះជាម្ចាស់អោយទ្រង់យាងមកជួយជាបន្ទាន់។ ស្តេចដាវីឌទូលថ្វាយដល់ព្រះជាម្ចាស់ ឥតមានអ្វីលាក់លៀមនៅក្នុងចិត្តរបស់លោកទេ។ យើងជាគ្រីស្តបរិស័ទត្រូវទូលថ្វាយដល់ព្រះជាម្ចាស់ កុំអោយមានការលាក់លៀមអ្វីនៅក្នុងចិត្តយើងអោយសោះ។

ឱព្រះយេហូវ៉ាអើយ សូមស្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំ សូមផ្ទៀងព្រះកាណ៌ស្តាប់សេចក្តីទូលអង្វររបស់ទូលបង្គំ សូមឆ្លើយតបមកទូលបង្គំផង ដោយសេចក្តីស្មោះត្រង់ និងសេចក្តីសុចរិតរបស់ទ្រង់ (ទំនុកដំកើង១៤៣:១)។

ដាវីឌអំពាវនាវសូមដល់ព្រះជាម្ចាស់ ដោយយល់ដល់សេចក្តីស្មោះត្រង់ និងសេចក្តីសុចរិតរបស់ព្រះអង្គ។ ចំណែកព្រះជាម្ចាស់វិញឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់ស្តេចដាវីឌនៅក្នុងករណីទាំងពីរយ៉ាងនេះដែរ។ ព្រះអង្គឆ្លើយតបយោលតាមស្មោះ

ត្រង់ និងសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ផ្ទាល់។ បើយើងលន់តួនូវអំពើបាបដែលយើងបានប្រព្រឹត្ត នៅចំពោះព្រះជាម្ចាស់ ព្រះអង្គមានសេចក្តីស្មោះត្រង់ និងអត់ទោសបាបដល់យើង។ គម្ពីរ១យ៉ូហាន១:៩ចែងថា "បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនឹងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង"។ ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ និងសុចរិត។ ព្រះបាទដាវីឌទូលថ្វាយដល់ព្រះជាម្ចាស់ ដោយទុកចិត្តលើសេចក្តីស្មោះត្រង់ និងសេចក្តីសុចរិតរបស់ព្រះជាម្ចាស់ជាព្រះដ៏ខ្ពស់។ យើងអធិស្ឋានទូលសូមដល់ព្រះជាម្ចាស់ ពឹងពាក់លើសេចក្តីស្មោះត្រង់ និងសេចក្តីសុចរិតរបស់ព្រះជាម្ចាស់។

ម្យ៉ាងទៀតគម្ពីរទំនុកដំកើងជំពូក១៤៣ ជាសេចក្តីអំពាវនាវរួមរបស់សាសន៍អ៊ីស្រាអែលចំពោះព្រះជាម្ចាស់។ សាសន៍អ៊ីស្រាអែលមានសេចក្តីសង្ឃឹមតែម្យ៉ាង ពេលដែលអំពាវនាវសូមជំនួយពីព្រះជាម្ចាស់ ពិសេសពេលដែលសាសន៍នេះជួបប្រទះនឹងសេចក្តីទុក្ខលំបាក។ ព្រះជាម្ចាស់មិនដែលធ្វើអោយគេខកចិត្តដោយប្រការណាមួយទេ បើគេពឹងពាក់ដល់ព្រះអង្គ ដោយយល់ដល់សេចក្តីស្មោះត្រង់ និងសេចក្តីសុចរិតរបស់ទ្រង់។

ព្រះជាម្ចាស់ នៅយកព្រះហឫទ័យទុកដាក់ចំពោះសាសន៍អ៊ីស្រាអែលនៅឡើយ។ គម្ពីរមីកា៧:២០ចែងថា "ទ្រង់នឹងសំរេចតាមសេចក្តីពិតដល់យ៉ាកុប នឹងតាមសេចក្តីសប្បុរសដល់អ័ប្រាហាំ ដូចជាទ្រង់បានស្បថនឹងពួកឰយុកោយើងរាល់គ្នា ចាប់តាំងពីបុរាណមកនោះ"។ រីឯគម្ពីរនិក្ខមនំ២:២៤-២៥ចែងដែរថា "ទ្រង់ឮដំងូររបស់គេ

ហើយក៏នឹកចាំពីសេចក្តីសញ្ញាដែលទ្រង់បានតាំងនឹងអ័ប្រាហាំ នឹងអ៊ីសាក ហើយនឹងយ៉ាកុបព្រះទ្រង់ឃើញពួកកូនចៅអ៊ីស្រាអែល ហើយក៏ជ្រាបដល់សេចក្តីទុក្ខរបស់គេ"។ ហេតុអ្វីបានជាព្រះជាម្ចាស់នៅតែគិតគូរដល់សាសន៍អ៊ីស្រាអែល? ពីព្រោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ និងសុចរិត។

ទូលបង្គំលើកដៃប្រណម្យដល់ទ្រង់ ព្រលឹងទូលបង្គំស្រេករកទ្រង់ ដូចជាដីហួតហែងស្រេករកទឹក (ទំនុកដំកើង១៤៣:៦)។

រដូវប្រាំងណាដែលគ្មានភ្លៀងកក់ម្តងសោះ ស្រែកឃ្លានទឹកយ៉ាងខ្លាំង។ ស្តេចដាវីឌទូលថ្វាយដល់ព្រះជាម្ចាស់ថា "...ព្រលឹងទូលបង្គំស្រេករកទ្រង់ ដូចជាដីហួតហែងស្រេករកទឹក"។

មិនតែប៉ុណ្ណោះ ស្តេចដាវីឌអំពាវនាវសូមដល់ព្រះជាម្ចាស់ទៀតថា

ឱព្រះយេហូវ៉ាអើយ សូមប្រញាប់នឹងឆ្លើយមកទូលបង្គំ ជីវិតវិញ្ញាណទូលបង្គំអន់ថយហើយ សូមកុំលាក់ព្រះភក្ត្រនឹងទូលបង្គំឡើយ ក្រែងទូលបង្គំនឹងត្រឡប់ដូចជាពួកអ្នកដែលចុះទៅក្នុងរណ្តៅ (ទំនុកដំកើង១៤៣:៧)។

ស្តេចដាវីឌទូលថ្វាយដល់ព្រះជាម្ចាស់ថា "ទ្រង់ជាព្រះតែមួយអង្គគត់ដែលមានសមត្ថភាពអាចជួយដល់ទូលព្រះបង្គំ"។

[9]សូមឱ្យទូលបង្គំបានឮសេចក្តីសប្បុរសរបស់ទ្រង់ នៅពេលព្រឹក ដ្បិតទូលបង្គំទុកចិត្តនឹងទ្រង់ សូមឱ្យទូលបង្គំបានស្គាល់ផ្លូវដែលគួរដើរ ពីព្រោះទូលបង្គំបានលើកព្រលឹងទៅរកទ្រង់ [10]ឱ ព្រះយេហូវ៉ាអើយ សូមជ្រោសទូលបង្គំ ឱ្យរួចពីពួកខ្មាំងសត្រូវ ទូលបង្គំរត់មកពឹងជ្រកនៅទ្រង់ [10]សូមបង្ហាត់បង្រៀនឱ្យទូលបង្គំបានប្រព្រឹត្តតាមព្រះហឫទ័យទ្រង់ ដ្បិតទ្រង់ជាព្រះនៃទូលបង្គំពិត សូមឱ្យព្រះវិញ្ញាណដ៏ល្អរបស់ទ្រង់ នាំទូលបង្គំចូលទៅក្នុងស្រុក ដែលប្រកបដោយសេចក្តីទៀងត្រង់ (ទំនុកដំកើង១៤៣:៨-១០)។

ខខាងលើជាការបញ្ជាក់អោយឃើញថា ស្តេចដាវីឌមានការទុកចិត្តដល់ព្រះជាម្ចាស់ឥតរង្គើឡើយ។ ចំពោះស្តេចដាវីឌ ព្រះជាម្ចាស់ជាទីពំនឹង និងជាទីសង្ឃឹមតែមួយគត់របស់លោក។ លោកអំពាវនាវសូមដល់ព្រះជាម្ចាស់ថា "សូមបង្ហាត់បង្រៀនឱ្យទូលបង្គំបានប្រព្រឹត្តតាមព្រះហឫទ័យទ្រង់ ដ្បិតទ្រង់ជាព្រះនៃទូលបង្គំពិត សូមឱ្យព្រះវិញ្ញាណដ៏ល្អរបស់ទ្រង់ នាំទូលបង្គំចូលទៅក្នុងស្រុក ដែលប្រកបដោយសេចក្តីទៀងត្រង់"។ សូមអោយសេចក្តីអធិស្ឋានខាងលើនេះ ជាសេចក្តីអធិស្ឋានរបស់យើងរាល់គ្នា

ដែលជាកូនរបស់ព្រះអង្គ។ យើងដើរជាមួយព្រះជាម្ចាស់រាល់ថ្ងៃ ត្រូវការព្រះអង្គ បង្ហាត់បង្រៀនអោយយើងចេះប្រព្រឹត្តតាមព្រះហឫទ័យទ្រង់។ សូមសេចក្តីអធិស្ឋាន ដែលព្រះបាទដាវីឌទូលថ្វាយដល់ព្រះជាម្ចាស់ ជាសេចក្តីអធិស្ឋានរបស់យើងរាល់គ្នាជា កូនរបស់ព្រះជាម្ចាស់ដែរ។

យើងស្វែងការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នា លើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"